កំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក

ខែមីនា ឆ្នាំ២០១៤

កំណែទម្រង់ដីធ្លី

ខ្លឹមសារសង្ខេប

កំណត់ត្រាសង្ខេបនេះបង្ហាញពីទិដ្ឋភាពទូទៅ និងការវិភាគពីព្រឹត្តិការណ៍នានានៅពេលថ្មីៗនេះរបស់ព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”) ដែលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កម្មសិទ្ធិដីធ្លី និងការចុះបញ្ជីដីធ្លី និងពិភាក្សាពីមូលហេតុផ្នែករចនាសម្ព័ន្ធ ផ្នែកគតិយុត្ត និងសង្គមដែលនៅពីក្រោយការដកហូតដីធ្លី និងរបៀបដែលរាជរដ្ឋាភិបាលកម្ពុជា (“រដ្ឋាភិបាល”) ខកខានក្នុងការការពារសិទ្ធិមនុស្ស ព្រមទាំងបានរំលោភបំពានសិទ្ធិទាំងនោះយ៉ាងសកម្ម និងផ្តល់អនុសាសន៍មួយចំនួនក្នុងគោលបំណងដោះស្រាយបញ្ហាទាំងនេះ។

ផ្នែកដំបូងនៃកំណត់ត្រាសង្ខេបនេះផ្តល់នូវទិដ្ឋភាពទូទៅជុំវិញសារវាតារនៃកម្មសិទ្ធិដីធ្លីក្នុងប្រទេសកម្ពុជា។ ផ្នែកទីពីរ ពិនិត្យមើលអំពីមូលហេតុសំខាន់នៃជម្លោះដីធ្លី នៅក្នុងប្រទេសកម្ពុជា ដោយរួមមាន៖ ការផ្តល់សម្បទានដីដ៏ច្រើនសន្ធឹកសន្ធាប់ ការខ្វះចន្លោះក្នុងការវាស់វែងដីធ្លី និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ ការបំភិតបំភ័យ និងអំពើហិង្សាដែល សហគមន៍បានប្រឈម ព្រមទាំងកង្វះយន្តការដោះស្រាយជម្លោះ។ ផ្នែកចុងក្រោយផ្តល់សេចក្តីសន្និដ្ឋានបញ្ចប់ជុំវិញស្ថានភាពដីធ្លីនាពេលបច្ចុប្បន្ននៅកម្ពុជា ដោយមានលើកឡើងនូវអនុសាសន៍ជាច្រើនរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ដែលនៅក្នុងចំណោមអនុសាសន៍ទាំងនេះ មានសំណើរសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- បង្កើតឲ្យមានសំណើរពិស្តា និងជាក់លាក់សម្រាប់កំណែទម្រង់ដីធ្លី ដោយបង្កើតឲ្យមានការពិគ្រោះយោបល់ជាមួយតួអង្គសង្គមស៊ីវិល និងសហគមន៍នានាដែលរងផលប៉ះពាល់។
- ជាក់បង្ហាញជាសាធារណៈនិងអាចចូលទៅកេបាននូវរាល់ព័ត៌មាននានាស្តីពីដីសម្បទានការធ្វើអនុប្បយោគដីរបស់រដ្ឋ និងតំបន់ការពារនានា។
- គោរពភាពជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ និងសិទ្ធិភោគៈ ហើយជៀសវៀងការបដិសេធ ឲ្យពលរដ្ឋទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីតាមរយៈកម្មវិធីរបស់រដ្ឋាភិបាល។
- ពន្លឿនដំណើរការចុះបញ្ជីដល់សហគមន៍ជនជាតិដើមភាគតិចដើម្បីទទួលប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាព។
- រៀបចំកម្មវិធីពិគ្រោះយោបល់ដ៏ច្បាស់លាស់ ប្រកបដោយអត្ថន័យជាមួយនឹងសហគមន៍ដែលរងផលប៉ះ-ពាល់ នៅពេលមានគម្រោងអភិវឌ្ឍបង្កើតឡើង។
- ធ្វើការវាយតំលៃពីផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម មុនពេលផ្តល់សម្បទានដី។
- បន្តការផ្អាកជាបណ្តោះអាសន្នពីការបណ្តេញប្រជាពលរដ្ឋចេញពីដីធ្លី។
- ធានាថា ទីកន្លែងតាំងទីលំនៅថ្មីទាំងអស់មានសេវានានាគ្រប់គ្រាន់។
- ធានាថាតួអង្គឯកជនត្រូវទទួលខុសត្រូវចំពោះការចាប់យកដីធ្លី និងការបណ្តេញចេញខុសច្បាប់នានា

- បញ្ឈប់នូវរាល់ការយាយីផ្នែកនយោបាយ តាមផ្លូវតុលាការ និងអំពើហិង្សាប្រឆាំងលើអ្នកតវ៉ាដោយសន្តិវិធីនានា។

កំណត់ត្រាសង្ខេបនេះ តាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការមិន-មែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។

សាវតារ៖ ប្រវត្តិដីធ្លីនៅកម្ពុជា

សាវតារនយោបាយដ៏រង្គោះរង្គើរបស់កម្ពុជាបានធ្វើឲ្យមានការផ្លាស់ប្តូរជាញឹកញាប់នូវក្របខ័ណ្ឌសិទ្ធិដីធ្លី ដែលពុំមានភាពមាំទាំនៅទូទាំងប្រទេស។ ជាពិសេស ការបង្កវិនាសកម្មនៃរបបខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលបានបំផ្លាញចោលនូវប្រព័ន្ធកម្មសិទ្ធិដីធ្លីឯកជន និងឯកសារដីធ្លីនានា ដែលនេះបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិដីធ្លីកាន់តែធ្ងន់ធ្ងរឡើង។

បន្ទាប់មកទៀត មុនមកដល់ឆ្នាំ១៩៩២[1] នៅពេលដែលច្បាប់ភូមិបាលថ្មីត្រូវបានរដ្ឋាភិបាលអនុម័ត ដែលអនុញ្ញាតឲ្យប្រជាពលរដ្ឋអាចកាន់កាប់លើដីឯកជន និងអាចធ្វើអនុប្បទានបាន។ ទោះជាយ៉ាងណាក្តី ច្បាប់ភូមិបា-លឆ្នាំ២០០១ មិនត្រឹមតែបានទទួលស្គាល់សិទ្ធិរបស់បុគ្គលក្នុងការកាន់កាប់លើដីធ្លី និងធ្វើអនុប្បទានប៉ុណ្ណោះទេ តែថែមទាំងផ្តល់នូវប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិដីធ្លី ដែលជាតម្រូវការចាំបាច់បំផុតនោះទៀតផង។[2] ច្បាប់បញ្ញត្តិផ្សេងៗ បានបង្កើតឡើងជាបន្តបន្ទាប់ ចំណោមច្បាប់ទាំងនោះក៏មានអនុក្រឹត្យលេខ១៤៦ ចេញកាលពីឆ្នាំ២០០៥ ដែលបានអនុញ្ញាតឲ្យរដ្ឋាភិបាលធ្វើការផ្តល់សម្បទានដីសេដ្ឋកិច្ច ដើម្បីផលប្រយោជន៍ពាណិជ្ជកម្ម និងការអនុម័តក្រមរដ្ឋប្បវេណីកម្ពុជាក្នុងឆ្នាំ២០១១។[3] ការអនុវត្តច្បាប់ និងបទបញ្ជាទាំងនេះ បានទទួលរងនូវការរិះគន់ជាខ្លាំង ដោយសារតែច្បាប់នេះបានបម្រើផលប្រយោជន៍ឲ្យតែជនមានទ្រព្យធន ជាជាងបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋខ្មែរសាមញ្ញ។

ដោយសារតែការរងគ្រោះនៃរបបខ្មែរក្រហម និងការអនុវត្តច្បាប់ពុំត្រឹមត្រូវ នាំឲ្យប្រជាពលរដ្ឋកម្ពុជាភាគច្រើនពុំមានប័ណ្ណកម្មសិទ្ធិដីធ្លី ហើយពួកគាត់កាន់តែងាយប្រឈមទៅនឹងការរំលោភបំពានសិទ្ធិ ជាពិសេសនៅក្នុងបរិបទមួយនៅពេលដែលការអភិវឌ្ឍសេដ្ឋកិច្ចបានរីកលូតលាស់យ៉ាងឆាប់រហ័សនោះ។ ម.ស.ម.ក ប៉ាន់ប្រមាណថា មានគ្រួសារប្រមាណ ៤៧,៦១៦ គ្រួសារ បានរងផលប៉ះពាល់ដោយទំនាស់ដីធ្លីនៅទូទាំងប្រទេសចាប់តាំងពីឆ្នាំ ២០០៧[4]មក ដោយប្រជាពលរដ្ឋខ្មែរ និងជនជាតិដើមភាគតិចត្រូវបានបដិសេធសិទ្ធិលំនៅដ្ឋាន សិទ្ធិដីធ្លី និងសិទ្ធិក្នុងការប្រកបរបរចិញ្ចឹមជីវិតរបស់ខ្លួន។។ មានការប៉ាន់ប្រមាណថា ប្រជាពលរដ្ឋ ១០ភាគរយ ក្នុងចំណោមចំនួន

[1]ច្បាប់ភូមិបាល ឆ្នាំ១៩៩២ ក្រឹត្យលេខ ០០១ (ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២(កាត់)។

[2]ច្បាប់ភូមិបាលឆ្នាំ២០០១ នស/រកម/០៨០១/១៤(ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១(កាត់)មាត្រា១០។

[3]ក្រមរដ្ឋប្បវេណី នស/រកម/១២០៧/០៣០(ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧)(កាត់)។

[4] "ផែនទីការរំលោភបំពាន" វិទាទដីធ្លីដែលបានរាយការណ៍ "វិគាគផ្នែកករណីដីធ្លី" (ខែវិច្ឆិកា ឆ្នាំ២០១៣) អាចរកបានលើគេហទំព័រ "សិទ្ធិ" http://bit.ly/1j1n9su។

ប្រជាពលរដ្ឋសរុប នៅរាជធានីភ្នំពេញ បានត្រូវបណ្តេញចេញដោយបង្ខំ ឬក៏ក្នុងករណី ខ្លះ ពួកគាត់ត្រូវបណ្តេញចេញតាមរយៈការរៀបចំលំនៅដ្ឋានថ្មីចាប់តាំងពីឆ្នាំ២០០១ មក។[5]

នៅប្រទេសកម្ពុជា មានកត្តាផ្សេងៗជាច្រើនរួមចំណែកក្នុងការបង្កជម្លោះ និងការដេកហូតដីធ្លី។ ការផ្តល់សម្បទានដី ការចុះបញ្ជីដីធ្លី និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិចន្លោះប្រហោង ការគំរាមកំហែង និងការបំភិតបំភ័យរបស់សហគមន៍ដែលរងគ្រោះ ព្រមទាំងកង្វះយន្តការដោះស្រាយជម្លោះ ប្រការទាំងអស់នេះ សុទ្ធតែជាការបង្កឲ្យមានទំនាស់ដីធ្លីកាន់តែធ្ងន់ធ្ងរឡើង។ ផ្នែកបន្ទាប់ នឹងពិនិត្យមើលលើបញ្ហានេះបន្ថែមទៀត។

មូលហេតុបណ្តាលឲ្យមានជម្លោះ និងការដេកហូតដីធ្លី

ទោះបីមានការការពារត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (“រដ្ឋធម្មនុញ្ញ”) និងបានបញ្ចូលក្នុងក្របខណ្ឌច្បាប់ជាតិ និងអន្តរជាតិយ៉ាងណាក្តី ក៏ រាជរដ្ឋាភិបាលអនុញ្ញាតឲ្យមានការរឹបអូសយកដីធ្លី និងធនធាននានា ដោយពុំបានគោរពតាមនីតិវិធីត្រឹមត្រូវ និងស្របតាមក្របខណ្ឌច្បាប់ ។ បញ្ហានេះគឺដោយសារតែជាផ្នែកមួយនៃអំពើពុករលួយ និងវប្បធម៌និទណ្ឌភីរកាលដាលក្នុងជួររាជរដ្ឋាភិបាល។

<u>សម្បទានដី</u>

ទំហំផ្ទៃដីដ៏ធំធេង បានត្រូវផ្ទេរឲ្យ និងនៅតែបន្តផ្ទេរពីសំណាក់រាជរដ្ឋាភិបាល ដើម្បីផលប្រយោជន៍ពាណិជ្ជកម្មក្នុងរូបភាពនៃសម្បទានដីសេដ្ឋកិច្ច សម្បទានដីសង្គមកិច្ច ការធ្វើអនុប្បយោគ និងតំបន់សេដ្ឋកិច្ចពិសេស។ ការផ្តល់សម្បទានដី ជារឿយៗ ធ្វើឡើងដោយ៖ (១) ពុំបានគោរពដល់សិទ្ធិទ្រព្យសម្បត្តិរបស់បុគ្គលឯកជន និងសិទ្ធិភោគៈ (២) ពុំប្រកាន់ខ្ជាប់តាមការកំណត់នៃច្បាប់ស្តីអំពីទំហំដីដែលអាចសម្បទាន (៣) ពុំបានចាត់ចំណាត់ថ្នាក់ឲ្យបានត្រឹមត្រូវជាមុននូវដីដែលត្រូវទទួលបានដោយស្របច្បាប់សម្រាប់ការធ្វើអនុប្បទាន (៤) ពុំបានធ្វើការវាយតម្លៃបឋមជាចាំបាច់អំពីផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម និង (៥) ពុំបានគោរពដល់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានការពិគ្រោះយោបល់ និងទទួលបានសំណងដោយយុត្តិធម៌។ ជាពិសេស បើទោះជាមានការកំណត់ដោយច្បាប់ពីការផ្តល់ទំហំសម្បទានដីសេដ្ឋកិច្ចមិនឲ្យច្រើនជាង១០.០០០ហិកតា សម្រាប់កម្មសិទ្ធិករម្នាក់ៗ[6]នោះក្តី ក៏មានម្ចាស់កម្មសិទ្ធិដីធ្លីជាច្រើនមិនគោរពតាមលក្ខខណ្ឌតម្រូវនេះទេ ដោយពួកគេបានចុះឈ្មោះជាច្រើនផ្សេងៗគ្នាសម្រាប់ក្រុមហ៊ុនរបស់ខ្លួន។

សម្បទានដីសេដ្ឋកិច្ច ត្រូវបានរាជរដ្ឋាភិបាលប្រើជាឧបករណ៍ ដើម្បីផ្ទេរទំហំផ្ទៃដីដ៏ធំធេងពីប្រជាពលរដ្ឋកម្ពុជា ក្នុងគោលបំណងដើម្បីផលប្រយោជន៍ពាណិជ្ជកម្ម ហើយការផ្តល់ សម្បទានដីនោះ គឺជាការផ្តល់រង្វាន់ទៅឲ្យជនមានទ្រព្យធន ដែលនាំឲ្យខាតបង់ផលប្រយោជន៍ធំធេងរបស់ប្រជាពលរដ្ឋកម្ពុជាសាមញ្ញ ។ យោងតាមការស្រាវជ្រាវរបស់ ម.ស.ម.ក បង្ហាញថា ផ្ទៃដីទំហំ ១,០៨៧,១៨៧.១០ ហិកតា ត្រូវបានរដ្ឋាភិបាលធ្វើសម្បទានក្នុងរូបភាពសម្បទានដីសេដ្ឋកិច្ចចាប់តាំងពីឆ្នាំ២០០៨ មក។[7]

---

[5] អង្គការលើកលែងទោសអន្តរជាតិ “ស្ថានភាពសិទ្ធិមនុស្សពិភពលោក” (របាយការណ៍) (ឆ្នាំ២០១២) អាចរកបានតាម៖ <http://bit.ly/1mJyJx2>។

[6]អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច លេខ. ១៤៦ អនគ/បក(ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥)(កាត់)។

[7] “អនុក្រឹត្យស្តីពីសម្បទានដី” អាចរកបាននៅលើគេហទំព័រ “សិទ្ធិ” http://bit.ly/1dpvVS7។

ជារឿយៗសម្បទានដីបាន ប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់ដីធ្លីដែលកំពុងតែកាន់កាប់ដោយសហគមន៍នានា។ ករណីថ្មីនេះៗ នៅក្នុងខេត្តស្ទឹងត្រែង អ្នកភូមិត្រូវបាន ដាក់នៅក្នុងតំបន់មួយ ហ៊ុំព័ទ្ធដោយដីដែលបានធ្វើសម្បទាន ដល់ក្រុមហ៊ុន ដោយកាត់ផ្តាច់ទាំងស្រុងពីធនធានសម្រាប់ទ្រទ្រង់ជីវិតជាមូលដ្ឋាន ដែលពួកគាត់ធ្លាប់តែអាស្រ័យផលមកកាលពីមុន។ ការរស់នៅរបស់អ្នកភូមិ ឡោមព័ទ្ធទាំងស្រុងដោយសម្បទានដីសេដ្ឋកិច្ច ពីរទឹកន្លែងដែលបានផ្តល់ទៅឲ្យ ក្រុមហ៊ុនវៀតណាម និងក្រុមហ៊ុនចិនកាលពីឆ្នាំ២០១០ បានធ្វើឲ្យអ្នកភូមិរស់នៅដោយកាពរឹតត្បិត មិនអាចចេញចូលទៅស្វែងរកអាហារ ទឹក និងធ្វើដំណើរលើផ្លូវថ្នល់។ ជីវិតរស់នៅរបស់ពួកគាត់បានធ្លាក់នៅក្នុងស្ថានភាពដូចអ្នកទោសនៅលើដីធ្លីរបស់ខ្លួនឯងយ៉ាងដូច្នោះ។[8]ការរឹតត្បិតនៃការទទួលបានទាំងនេះ គឺជាការរំលោកទាំងស្រុងទៅនឹងមាត្រា៥៨ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ដែលចែងថា សម្បទានដីសេដ្ឋកិច្ច *"មិនអាចប៉ះពាល់ផ្លូវគមនាគមន៍ ដីចំណីផ្លូវ និងដីចាំបាច់សម្រាប់ថែទាំ ក៏ដូចជា ផ្លូវទឹក ត្រពាំង បឹង និងដែនទឹកបម្រុង ដែលមានប្រយោជន៍ដល់ការរស់នៅរបស់ប្រជាពលរដ្ឋឡើយ"*។[9] ឧទាហរណ៍ករណីផ្សេងទៀត ដោយលើកឡើងពីផលប៉ះពាល់ដោយសារការបណ្តេញចេញ នោះគឺករណីនៅភូមិព្រែកដីក ខេត្តកោះកុង ដែលប្រាក់ចំណូលប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋរងគ្រោះដោយសារការបណ្តេញចេញទាំងបង្ខំទាំងនោះបានធ្លាក់ចុះពី ២០៧០,១០ដុល្លា មកនៅត្រឹម ៣១៥,៨៩ ដុល្លាអាមេរិក។[10] សម្បទានដីសេដ្ឋកិច្ចទាំងនេះ ពុំគួរណាត្រូវបាន ផ្តល់ទៅឲ្យក្រុមហ៊ុននោះទេ រាជរដ្ឋាភិបាលគួរគោរពដល់សិទ្ធិរបស់អ្នកភូមិដោយធ្វើការវាយតម្លៃពីផលប៉ះពាល់សង្គមមុនពេលធ្វើការសម្រេចចិត្តណាមួយ។

នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ រាជរដ្ឋាភិបាលបានចេញបទបញ្ជាផ្អាកការផ្តល់សម្បទានដីជាបណ្តោះអាសន្ន តាម ("បទបញ្ជាលេខ ០១") [11] ជាវិធានការមួយដើម្បីកែតម្រូវបញ្ហាកំពុងតែកើតឡើងនៅជុំវិញសម្បទានដី។ បទបញ្ជានោះ ស្នើឲ្យធ្វើការហាមឃាត់ការផ្តល់សម្បទានដីថ្មីនានា ឲ្យធ្វើការវាយតម្លៃទៅលើសម្បទានដីដែលមានស្រាប់ទាំងអស់ ដកហូតយកមកវិញនូវសម្បទានដីទាំងឡាយណាដែលរកឃើញថារំលោក បញ្ញត្តិច្បាប់ និងកិច្ចសន្យា។[12] តែយ៉ាងណាក្តី មានការខ្វះចន្លោះសំខាន់មួយ កើតឡើងនៅក្នុងការផ្អាកបណ្តោះអាសន្ននេះ ដោយសារការផ្អាកសម្បទានដីសេដ្ឋកិច្ចនេះគឺគ្រាន់តែធ្វើឡើងឲ្យល្អមើល ខណៈដែលសេចក្តីប្រកាសផ្អាកនោះត្រូវបានអនុវត្តប្រាសចាកខ្លឹមសាររបស់ខ្លួន[13]។ ក្រោយមកទៀត មានការផ្តល់សម្បទានដីសេដ្ឋកិច្ចចំនួន៩កន្លែងទៅឲ្យក្រុមហ៊ុននៅឆ្នាំ២០១២ បន្ទាប់ពីបទបញ្ជាឲ្យផ្អាកសម្បទានដីនោះចូលជាធរមាន ដោយសរុបមានផ្ទៃដីទំហំប្រមាណ

[8] កក្តិ ស៊ាងលី និង ប្រ៊ីហ្គេត ឌឺ ខេតុ "ដាក់អ្នកភូមិឲ្យរស់នៅឯកការ ស្តមស្តាំង" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១២។

[9] ច្បាប់ស្តីពីព្រៃឈើ "ជំពូក៩៖អ្នកប្រើសិទ្ធិបែបប្រពៃណី ការគ្រប់គ្រងលើព្រៃសហគមន៍ និងព្រៃឯកជន។

[10] ម.ស.ម.ក "កម្ពុជា៖ "ជម្លោះដីធ្លី ទិដ្ឋភាពនៃស្ថានភាពដីធ្លី" (របាយការណ៍) (ខែធ្នូ ឆ្នាំ២០១៣) អាចរកបានតាមរយៈ: http://www.cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=104&id=5&lang=khm។

[11] សេចក្តីបង្គាប់ស្តីពីការពង្រឹងវិធានការណ៍ និងប្រសិទ្ធភាពនៃការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច លេខ ០១ខខ (ខែឧសភា ឆ្នាំ២០១២) ("សេចក្តីបង្គាប់ ០១") អាចរកបានតាម៖ <http://bit.ly/1hcN4lm>។

[12] មានប្រភពដូចខាងលើ។

[13] សមាគមអាដហុក "ឈានដល់ចំណុចមួយ" ? សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាន និងសិទ្ធិអាស្រ័យផលធនធានធម្មជាតិនៅកម្ពុជា នៅឆ្នាំ២០១២" (ខែកុម្ភៈ ឆ្នាំ២០១៣) អាចរកបានតាម៖ http://bit.ly/1eFH8wu>។

៦៦,៣១៤ ហិកតា។[14] ជាងនេះទៀត លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យពិចារណាលើសម្បទានដីសេដ្ឋកិច្ចដែលត្រូវបានផ្តល់រួចរាល់ហើយដើម្បីកំណត់ឲ្យបានស្របតាមច្បាប់នោះមិនត្រូវបានលាតត្រដាងឡើយ ដូច្នេះហើយ បទបញ្ជាផ្ទាកផ្តល់ដីសម្បទាននេះ ខ្វះតម្លាភាពទាំងស្រុង។

ទោះជារាជរដ្ឋាភិបាលបានអនុវត្តតាមបទបញ្ជាលេខ ០១ នេះនៅក្នុងឆ្នាំ២០១៣ នោះក្តី ការផ្តល់សម្បទានដីសង្គមកិច្ចជាច្រើន មានច្រើនជាងប្រាំដង ពីតួលេខដែលទទួលបាននៅក្នុងឆ្នាំ២០១២ បង្ហាញថា នៅក្នុងឆ្នាំ ២០១២ មានផ្ទៃដីសម្បាទានសង្គមកិច្ចតែត្រឹម ៨៣ កន្លែង សរុបស្មើ ២៦០,៧៦២ ហិកតាប៉ុណ្ណោះ ប៉ុន្តែនៅក្នុងឆ្នាំ ២០១៣ មានការផ្តល់សម្បទានដីសង្គមកិច្ចចំនួន៤២០កន្លែង ដែលមានផ្ទៃដីសរុបរហូតដល់ ៥០២,៤០៤.៤៩ ហិកតា។[15] តែអ្វីដែលជាការព្រួយបារម្ភខ្លាំងនោះ គឺការបណ្តេញប្រជាពលរដ្ឋចេញពីដីធ្លីដោយបង្ខំ ដើម្បីត្រួសត្រាយផ្លូវសម្រាប់សម្បទានដីសង្គមកិច្ច ដែលករណីនេះ កាន់តែធ្វើឲ្យមានការព្រួយបារម្ភ ទោះជាមានបទបញ្ជាឲ្យផ្អាកសម្បទានដីសេដ្ឋកិច្ចនេះក្តី ក៏ការរឹបអូសយកដីធ្លី និងជម្លោះដីធ្លីនៅតែបន្តមានជាដដែល។

ការចុះបញ្ជី និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីមិនគ្រប់គ្រាន់

មានរបបសិទ្ធិចំនួនពីរលើទ្រព្យសម្បត្តិឯកជន នៅក្រោមច្បាប់ភូមិបាលគឺ៖ សិទ្ធិកម្មសិទ្ធិ និងសិទ្ធិភោគៈ។ ក្នុងករណីពុំមានប័ណ្ណរឹង ភោគីមានសិទ្ធិលើដីធ្លីរបស់ខ្លួន ប្រសិនបើលក្ខន្តិកៈច្បាស់លាស់ត្រូវបានបំពេញ៖ ភោគីនោះបានកាន់កាប់ដីនោះនៅមុនខែសីហា ឆ្នាំ២០០១ ហើយភោគៈនោះត្រូវបានកាន់កាប់ដោយពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន ឬដោយសុចរិត។[16] ដីភោគៈនោះត្រូវចុះបញ្ជីនៅភ្នាក់ងាររដ្ឋាភិបាលថ្នាក់មូលដ្ឋាន មិនមែនចុះបញ្ជីនៅថ្នាក់ជាតិនោះទេ។ បុគ្គលឯកជនអាចទាមទារសិទ្ធិកាន់កាប់ដីធ្លីរបស់ខ្លួនដោយពេញលេញ ក្នុងករណីដីនោះបានត្រូវចុះបញ្ជីនៅថ្នាក់ជាតិ ហើយគណៈកម្មាធិការសុរិយោដីត្រូវចេញប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ។[17] ទោះបីជាដីឯកជនត្រូវបានការពារពីការបណ្តេញចេញនោះក្តី ក្រុមហ៊ុនពាណិជ្ជកម្មដែលស្វែងរកដីវិនិយោគកំពុងតែបង្កឲ្យមានបញ្ហាប្រឈមដល់អ្នកភូមិដែលពុំមានប័ណ្ណកម្មសិទ្ធិដីធ្លី។

ប្រទេសកម្ពុជា ខ្វះសមត្ថភាពគ្រប់គ្រងលើការចុះបញ្ជី និងចេញប័ណ្ណកម្មសិទ្ធិដីធ្លីសម្រាប់ទូទាំងប្រទេស។ បន្ថែមពីនេះ ម្ចាស់ដីដែលអាចនឹងក្លាយជាកម្មសិទ្ធិករភោគច្រើនពុំមានឯកសារណាមួយដែលពួកគេត្រូវការដើម្បីអាចទទួលបានប្លង់រឹងទាំងនោះទេ ហើយភាគច្រើនពួកគាត់ពុំមានលទ្ធភាពក្នុងការចំណាយតម្លៃផ្សេងៗបន្ថែមដើម្បីទទួលបានប្លង់រឹងនោះទេ។[18] បន្ថែមលើបញ្ហាទាំងអស់នេះ គឺភាពគ្មានឆន្ទៈរបស់ រដ្ឋាភិបាល ក្នុងការជួយប្រជាពលរដ្ឋខ្លួនក្នុងការចុះបញ្ជី និងរក្សាការពារដីធ្លីរបស់ប្រជាពលរដ្ឋ ដែលបានបង្ហាញពីការខកខានរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់នូវព័ត៌មានពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ និងជំនួយដល់ប្រជាពលរដ្ឋ តែបែរជា ជ្រៀតជ្រែកយ៉ាង

---

[14] ម.ស.ម.ក "ការឃ្លាំមើលសម្បទានដីនៅកម្ពុជារបស់ ម.ស.ម.ក នៅក្នុងឆ្នាំ២០១២" (របាយការណ៍សង្ខេប) (ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០១៣) អាចរកបានតាម៖ <http://bit.ly/1hNHOlv> ។

[15] "អនុក្រឹត្យស្តីពីសម្បទានដី" អាចរកបានតាមរយៈគេហទំព័រ "សិទ្ធិ" http://bit.ly/1dpvVS7។

[16] ច្បាប់ភូមិបាល មាត្រា ៣៨។

[17] ច្បាប់ភូមិបាល សង្ខានុក្រម ("លទ្ធកម្មនៃកម្មសិទ្ធិ")។

[18]ប្រកាសអន្តរក្រសួងស្តីពី ការកំណត់ពីប្រាក់ចំណូលបានមកពីថ្លៃសេវានៃសុរិយោដី លេខ.៣៧៧ សហវ(ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០២) (កាត់)។

សកម្ម ជាមួយអ្នកដទៃក្នុងការធ្វើដូច្នោះទៅវិញ។ ឧបសគ្គក្នុងការទទួលបានប្លង់រឹង មានន័យថា ដីកម្មសិទ្ធឯកជនភាគច្រើន គឺនៅក្រោមសិទ្ធិកាន់កាប់បណ្តោះអាសន្ន មិនមែនជាម្ចាស់កម្មសិទ្ធិលើដីស្តាពរនោះទេ។

រដ្ឋាភិបាលពុំមានលទ្ធភាពគ្រប់គ្រាន់ផ្នែករដ្ឋបាលក្នុងការកត់ត្រា និងបង្កើតបញ្ជីកម្មសិទ្ធិលើដីធ្លីដែលសាធារណៈជនអាចរកបាន។ នៅពេលដែល រដ្ឋាភិបាលបានអនុញ្ញាតឲ្យមានជាលើកដំបូងចំពោះការចែក និងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនៅឆ្នាំ១៩៩២ ប្រជាពលរដ្ឋចំនួន ៤,៥លាននាក់ដំបូងបានចុះបញ្ជីដីធ្លីពីមន្ត្រីចុះបញ្ជីដីធ្លី។[19] ដោយមានជំនាញ និងធនធានតិចតួច ឬទទួលខុសត្រូវចំពោះកិច្ចការងារដ៏ច្រើនបែបនេះនោះ ការិយាល័យចុះបញ្ជីបានក្លាយជាកន្លែងកកស្ទះភ្លាម ហើយការបំពេញការងារមិនទទួលបានប្រសិទ្ធភាពឡើយ។

នៅចន្លោះឆ្នាំ២០០២ ដល់ឆ្នាំ២០០៩ ធនាគារពិភពលោក ក្នុងនាមដៃគូជាមួយប្រទេសមួយចំនួន បានសហការជាមួយរាជរដ្ឋាភិបាល ដើម្បីបង្កើតនូវប្រព័ន្ធចុះបញ្ជីដីធ្លីបែបទំនើប។[20] តែយ៉ាងណាក្តី គម្រោងនេះពុំមានលទ្ធភាពអនុវត្តទៅបានដោយជោគជ័យនូវគោលដៅក្នុងការចុះបញ្ជី និងការរក្សាគល់បញ្ជី ដែលខ្លួនបានកំណត់តាំងពីដំបូង។[21] ពលរដ្ឋដែលរស់នៅលើដីធ្លីមានទំនាស់ជាច្រើនមិនទទួលបានប្រព័ន្ធចុះបញ្ជីដីធ្លីបែបទំនើបនេះទេ រួមទាំងប្រជាពលរដ្ឋដែលកំពុងរស់នៅតំបន់បឹងកក់នោះផង។ នៅក្នុងឆ្នាំ២០១១ រដ្ឋាភិបាលបានបញ្ឈប់ប្រព័ន្ធចុះបញ្ជីដីធ្លីបែបទំនើបនេះមុនកាលកំណត់ បន្ទាប់ពីធនាគារពិភពលោកបានព្យួរមូលនិធិរបស់ខ្លួនបន្ទាប់ពីមានបណ្តឹងរបស់ប្រជាពលរដ្ឋនៅតំបន់បឹងកក់។ ពាក្យបណ្តឹងនោះបានលើកឡើងថា គ្រួសារជាច្រើនឥឡូវនេះកំពុងតែប្រឈមនឹងការបណ្តេញចេញ ដោយសារថា ប្រជាពលរដ្ឋទាំងនោះត្រូវបានបដិសេធទទួលបានការចុះបញ្ជីដីធ្លីបែបទំនើប ហើយកម្មវិធីចុះបញ្ជីដីធ្លីនោះខកខានពុំបានអនុវត្តតាមគោលនយោបាយការពាររបស់ធនាគារពិភពលោកឡើយ។

នៅចុងខែមិថុនា ឆ្នាំ២០១២ និស្សិតស្ម័គ្រចិត្តជាង១.០០០នាក់ ត្រូវបានបញ្ជូនទៅតាមបណ្តាខេត្តមួយចំនួននៅក្នុងប្រទេសកម្ពុជា និងបានចាប់ផ្តើមអនុវត្តយុទ្ធនាការផ្តល់ប័ណ្ណដីធ្លីថ្មីរបស់រាជរដ្ឋាភិបាល។ យោងតាមរដ្ឋាភិបាល គិតចាប់ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ប័ណ្ណកម្មសិទ្ធិដីធ្លីចំនួន ៣៨០.០០០ ត្រូវបានចែកជូនដល់ប្រជាពលរដ្ឋ។ តែយ៉ាងណាក្តី បែបបទអនុវត្តយុទ្ធនាការថ្មីនោះ រហូតមកទល់នឹងពេលនេះ មានការលើកឡើងនូវការព្រួយបារម្ភជាខ្លាំង។ ដោយគ្រាន់តែធ្វើការបណ្តុះបណ្តាលក្នុងរយៈពេលពីរថ្ងៃ ជាមួយនឹងកង្វះសិទ្ធិសម្រេចព្រមទាំងកង្វះបទពិសោធន៍ផងនោះ និស្សិតស្ម័គ្រចិត្តទាំងនេះពុំអាចបំពេញការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាពនោះទេ។ ប្រជាពលរដ្ឋជាច្រើនគ្រួសារបានរាយការណ៍ថា ពួកគាត់កំពុងតែប្រឈមនឹងបញ្ហាសំខាន់ៗ មួយចំនួន ដូចជាពុំទទួលបានឯកសារប័ណ្ណកម្មសិទ្ធិដីធ្លី អាជ្ញាធរដកហូតយកប័ណ្ណដីធ្លី រីឯប្រជាពលរដ្ឋដទៃខ្លះទៀតបានបាត់បង់ដីធ្លីក្នុងអំឡុងពេលដំណើរការវាស់វែងនោះតែម្តង។ ជាងនេះទៀត យុទ្ធនាការនោះមិនបានវាស់វែងនូវតំបន់ដីដែលមានទំនាស់ និងដីសមូហភាពរបស់ជនជាតិដើមភាគតិចនោះទេ ជាពិសេស ដីរបស់ពលរដ្ឋដែលងាយប្រឈមនឹងការបណ្តេញចេញ។

---

[19] អង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិ ‘ការគ្រប់គ្រងដីធ្លី នៅក្រោយពីជម្លោះដីធ្លីនៅកម្ពុជា’ (ឆ្នាំ២០១៤) ហ្វិច អាចរកបានតាម៖ <http://bit.ly/1gD1Krv>។

[20] ធនាគារពិភពលោក គម្រោងរៀបចំ និងគ្រប់គ្រងដីធ្លី អាចរកបានតាម៖www.worldbank.org/projects/P070875/land-management-administration-project?lang=en

[21] ធនាគារពិភពលោក ‘ សេចក្តីថ្លែងការណ៍ពីធនាគារពិភពលោក ស្តីពីការបញ្ចប់ដោយរាជរដ្ឋាភិបាលកម្ពុជាលើគម្រោងគ្រប់គ្រង និងរៀបចំដីធ្លី’ (ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៩) អាចរកបានតាម៖http://go.worldbank.org/TFCTB1QZK0

ការលើកឡើងពីភាពពុំមានប្រសិទ្ធភាពនៃយុទ្ធនាការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីនេះគឺជាករណីឧទាហរណ៍មួយ បានរាយការណ៍នៅលើបណ្តាញព័ត៌មាន ស្តីពីករណីនៅភូមិមួយក្នុងខេត្តបាត់ដំបង នៅពេលដែលអ្នកភូមិទទួលបានលិខិតមួយច្បាប់ចេញដោយរាជរដ្ឋាភិបាល និងត្រូវបានចុះហត្ថលេខាដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយផ្តល់ទំហំដីចំនួន៥៥៨ ហិកតា ដល់ប្រជាពលរដ្ឋចំនួន៤១៥គ្រួសារ។ បើទោះជាមានលិខិតចេញដោយរាជរដ្ឋាភិបាលនេះក្តី និស្សិតស្ម័គ្រចិត្តត្រូវបានចាត់ឲ្យវាស់វែងដីនោះតាមបញ្ជារបស់អាជ្ញាធរមូលដ្ឋាន ដោយដំទាស់នឹងលិខិតរបស់រាជរដ្ឋាភិបាលនោះ។ ជាលទ្ធផល ក្រុមនិស្សិតស្ម័គ្រចិត្តទាំងនោះ ត្រូវបានណែនាំមិនឲ្យអើពើ នឹងលិខិតរបស់រដ្ឋាភិបាល ហើយពួកគេបានវាស់វែងទំហំដីតិចជាង៥០០ហិកតា ដោយទុកទំហំផ្ទៃដីស្មើគ្នានេះទៅប្រគល់ឲ្យក្រុមហ៊ុនអាជីវកម្ម។[22]

យុទ្ធនាការផ្តល់បណ្ណកម្មសិទ្ធិដីធ្លីមិនបានសម្រេចជាដុំកំភួន ដោយសារតែភាពស្មុគ្រស្មាញនៃដំណើរការចុះបញ្ជី ជាពិសេស ការចុះបញ្ជីដីធ្លីសម្រាប់ប្រជាពលរដ្ឋជនជាតិដើមភាគតិច។ ច្បាប់ភូមិបាលឆ្នាំ២០០១ ចែងយ៉ាងច្បាស់ថា សិទ្ធិរបស់ប្រជាពលរដ្ឋជនជាតិដើមភាគតិចលើកម្មសិទ្ធិសមូហភាពត្រូវបានបង្កើតឡើង និងត្រូវបានទទួលស្គាល់។[23] ប៉ុន្តែ ការចែកបណ្ណដីធ្លីសមូហភាព មានលក្ខណៈមិនសមហេតុផលទាល់តែសោះ ដោយសារថាមានសហគមន៍ចំនួនតែ៥ប៉ុណ្ណោះ ក្នុងចំណោមសហគមន៍ចំនួន១១៤[24] បានដាក់ពាក្យស្នើសុំបណ្ណកម្មសិទ្ធិដីធ្លីដោយបំពេញតាមបែបបទសព្វគ្រប់។[25] ដំណើរការចុះបញ្ជីនៃបណ្ណដីធ្លីបែបសមូហភាព មានការអូសបន្លាយពេលនិងមានលក្ខណៈស្មុគ្រស្មាញជាទីបំផុត។ តាមការអនុវត្តមាន ១១ ដំណាក់កាល ដែលតម្រូវឲ្យសហគមន៍ចុះឈ្មោះខ្លួនឯងជាមុនសិន ហើយបន្ទាប់មកទើបអាចដាក់ពាក្យស្នើសុំបណ្ណកម្មសិទ្ធិដីធ្លីបាន ហើយដំណើរការនេះជាប់ពាក់ព័ន្ធជាមួយក្រសួងរដ្ឋាភិបាលចំនួន៣។ ដូចនេះ ប្រជាពលរដ្ឋជនជាតិដើមភាគតិច បានប្រឈមនឹងការចាប់យកដីធ្លីការទន្ទ្រានលើដីធ្លីរបស់ដូនតារបស់ពួកគាត់ និងបានគំរាមនឹងការបាត់បង់ទំនៀមទម្លាប់ និងវប្បធម៌របស់ខ្លួន។ ការរំលោភបំពានលើសិទ្ធិរបស់ជនជាតិដើមភាគតិច បានកើតឡើងនៅក្នុងខេត្តមណ្ឌលគីរី ជាកន្លែងដែលរាជរដ្ឋាភិបាលបានប្រគល់ផ្ទៃដីទំហំប្រហែល ១០.០០០ហិកតា ក្នុងរូបភាពសម្បទានដីសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុន សូហ្វីន ខេស៊ី ឌី សម្រាប់ដាំកៅស៊ូ ចាប់តាំងពីឆ្នាំ២០០៨។ ប្រជាពលរដ្ឋសហគមន៍ ជនជាតិដើមភាគតិច ក្នុងចំនួន៨៥០គ្រួសារដែលកាន់កាប់លើដីនោះ បានរងផលប៉ះពាល់ដោយសារសម្បទាននេះ។ អ្នកភូមិបានរាយការណ៍ថា ពួកគាត់បានទទួលរងផលប៉ះពាល់ទាំងផ្លូវកាយ ក៏ដូចជាផ្នែកស្មារតី គឺដោយសារមកពីការធ្វើឲ្យប៉ះពាល់លើដីព្រៃ និងដីបញ្ចុះ

[22] ម៉ែ ទិត្យថារ៉ា "ជម្លោះដីធ្លីបង្វែរទៅតុលាការវិញ" កាសែត *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១២ អាចរកបានតាម៖ www.phnompenhpost.com/index.php/2012112059821/National-news/land-dispute-back-in-court.html។

[23] ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា ២៣ និងមាត្រា ២៨។

[24] ហ្វ្រង់ ហ៊ូឃើ ម៊ូលើ និង ហ្គាន់ធើ ហ្សាល់ឌើហ្វ "គោលនយោបាយចាស់ សកម្មភាពថ្មី៖ ការផ្តួចផ្តើមផ្នែកនយោបាយដ៏គួរឲ្យភ្ញាក់ផ្អើលមួយក្នុងការទទួលស្គាល់សិទ្ធិមនុស្សនៅក្នុងកំណែទម្រង់ដីធ្លីកម្ពុជា" សន្និសិទ្ធប្រចាំឆ្នាំរបស់ធនាគារពិភពលោកស្តីពីដីធ្លី និងភាពក្រីក្រឆ្នាំ២០១៣ ថ្ងៃទី១១ដល់ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៣។

[25] ការិយាល័យឧត្តមក្រុមប្រឹក្សាសិទ្ធិរបស់ អ.ស.ប "សហគមន៍ជនជាតិដើមភាគតិចទទួលបណ្ណដីធ្លីនៅឃុំ") (ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០១) អាចរកបានតាម៖http://bit.ly/Hxp24M ។

សពដូនតារបស់ពួកគាត់។[26] ផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនេះបានកើតឡើងរួចមកហើយទោះបីបានរំលោភបំពានលើច្បាប់ភូមិបាលក៏ដោយ។

<u>ការគំរាមកំហែង និងការបំភិតបំភ័យពីសំណាក់រដ្ឋាភិបាល និងបុគ្គលិកក្រុមហ៊ុន</u>

ជាញឹកញាប់ រដ្ឋាភិបាលប្រើវិធីសាស្ត្របំភិតបំភ័យ និងប្រើអំពើហិង្សាខាងរាងកាយលើប្រជាពលរដ្ឋខ្លួនឯង ដើម្បីបណ្តេញប្រជាពលរដ្ឋទាំងនោះចេញពីដីធ្លី ជាជាងផ្តល់នូវនីតិវិធីមួយប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ជាការឆ្លើយតបនឹងការតវ៉ាជំទាស់របស់ពលរដ្ឋដែលសុំឲ្យមានដំណោះស្រាយដោយយុត្តិធម៌។ នៅមុនការបណ្តេញចេញ ជារឿយៗ ក្រុមហ៊ុនប្រើមន្ត្រីសន្តិសុខ ឬកងកំលាំងសន្តិសុខរដ្ឋ ដើម្បីការពារសម្បទានដីរបស់ក្រុមហ៊ុន ដែលជារឿយៗឈានដល់ការបំផិតបំភ័យ ការយាយីទៅលើសហគមន៍មូលដ្ឋាន។ នេះជាករណីធម្មតាទៅហើយ ចំពោះការបណ្តេញប្រជាពលរដ្ឋចេញពីដីធ្លី ដោយកម្លាំងហិង្សាហួសហេតុពីសំណាក់អាជ្ញាធរ។

ករណីដ៏ល្បីរន្ទឺក្នុងការប្រើកម្លាំងហួសហេតុដើម្បីបណ្តេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋានគឺករណី នៅបុរីកីឡា។ កាលពីដំបូងឡើយ បុរីកីឡាមានផ្ទៃដីទំហំ ១៤.១២ ហិកតា មានទីតាំងនៅចំកណ្តាលរាជធានីភ្នំពេញ ដែលមានប្រជាពលរដ្ឋចំនួន១.៧៧៦គ្រួសារតាំងទីលំនៅ។ នៅក្នុងឆ្នាំ២០០៣ រដ្ឋាភិបាលបានប្រគល់សម្បទានដីសង្គមមានទំហំ៤.៦ហិកតា នៅបុរីកីឡាឲ្យទៅក្រុមហ៊ុន *ផានអ៊ីម៉ុច*។ ក្រោមកិច្ចព្រមព្រៀងមួយ ក្រុមហ៊ុនផានអ៊ីម៉ុច បានសន្យាសាងសង់អាគារចំនួនដប់លើផ្ទៃដីទំហំពីរហិកតាអោយអ្នកភូមិបុរីកីឡា និងជាការផ្លាស់ប្តូរ ដើម្បីទទួលបានសិទ្ធិអភិវឌ្ឍលើទំហំផ្ទៃដីដែលនៅសល់ចំនួន ២.៣ ហិកតា។ បន្ទាប់ពីបានសាងសង់បានតែត្រឹមអាគារចំនួន៨ ក្នុងចំណោមអាគារចំនួន១០សម្រាប់អ្នកភូមិ ក្រុមហ៊ុន *ផានអ៊ីម៉ុច* បានស្នើសុំដីពីរដ្ឋាភិបាលនូវដីដែលត្រូវសាងសង់អាគាចំនួន២ ទៀតសម្រាប់អ្នកភូមិនោះ ទុកជារបស់ក្រុមហ៊ុនទៅវិញ ដោយអះអាងថាខ្វះថវិកា ហើយបានទុកឲ្យប្រជាពលរដ្ឋចន្លោះពី៣០០ ទៅ៤០០គ្រួសារគ្មានលំនៅដ្ឋានអចិន្ត្រៃយ៍ ។[27] នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១២ មានប្រជាពលរដ្ឋចំនួន ៣០០គ្រួសារបានបន្តរស់នៅក្នុងបុរីកីឡា ត្រូវបានអាជ្ញាធរបណ្តេញចេញដោយហិង្សាពីលំនៅដ្ឋានរបស់ខ្លួន។ កម្មករសំណង់បានបំផ្លិចបំផ្លាញលំនៅដ្ឋានរបស់ពួកគាត់ អមដោយកម្លាំងសន្តិសុខបានប្រើគ្រាប់ដំរ និងឧស្ម័នបង្ហូរទឹកភ្នែកប្រឆាំងអ្នកភូមិ។ មានមនុស្សជាង៦៤នាក់ បានរងរបួស ហើយមនុស្សចំនួន៨នាក់ត្រូវបានអាជ្ញាធរចាប់ខ្លួនក្នុងអំឡុងការបណ្តេញចេញនោះ។[28]

ជាងនេះទៀត សកម្មជនដីធ្លីដែលព្យាយាមជំទាស់នឹងការបណ្តេញចេញដោយបង្ខំ និងការពារសិទ្ធិរបស់ខ្លួន ជានិច្চកាលត្រូវបានយាយី និងដាក់ពន្ធនាគារដោយពុំមានមូលដ្ឋានច្បាប់ត្រឹមត្រូវ។ របាយការណ៍នាពេលថ្មីៗនេះ អះអាងដោយសំដៅលើការប្រើប្រាស់កម្លាំងដែលបង្កឲ្យមានគ្រោះថ្នាក់ដល់អាយុជីវិតលើសកម្មជនទាំងនោះ

---

[26] ហ្វីដ "ផលប៉ះពាល់នៃចំការកៅស៊ូរបស់ក្រុមហ៊ុន សូហ្វីន ខេស៊ីឌី លើដីធ្លីសហគមន៍ជនជាតិដើមភាគតិច នៅប៊ូស្រា ខេត្តមណ្ឌលគីរី (របាយការណ៍) (ខែតុលា ឆ្នាំ២០១១) អាចរកបានតាម៖ http://bit.ly/1jNbQJA។

[27] ម.ស.ម.ក "ប្រទេសកម្ពុជា៖ ដីធ្លីស្ថិតនៅក្នុងទំនាស់ ទិដ្ឋភាពទូទៅនៃស្ថានភាពដីធ្លី" (របាយការណ៍) (ខែធ្នូ ឆ្នាំ២០១៣) អាចរកបានតាម៖ <http://bit.ly/1jNbQJA>។

[28] របាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិឆ្នាំ២០១៣ "ស្ថានភាពសិទ្ធិមនុស្សនៅទូទាំងពិភពលោក" សន្ទសន្យន៍៖ ផ្ទុល ១០/០០១/២០១៣ អាចរកបានតាម៖ <http://bit.ly/1j1p4x8>។

នៅឆ្នាំ២០១២ គឺជាឆ្នាំដែលប្រមូលបានករណីអំពើហិង្សាច្រើនជាងគេបំផុត។[29] ពាក់ព័ន្ធទៅនឹងករណីនៅបុរីកីឡា កាលពីខែតុលា ឆ្នាំ២០១៣ នគរបាលបានប្រើដំបង ហើយបានវាយអ្នកតវ៉ា ដែលស្នើសុំឲ្យអភិបាលរាជធានីភ្នំពេញ លោក ប៉ា សុជាតិវង្ស គោរពតាមការសន្យារបស់លោកក្នុងការដោះស្រាយទំនាស់ដីធ្លីរបស់ប្រជាពលរដ្ឋបុរីកីឡា។ ការប្រើកម្លាំងលើសលុបដោយហិង្សាពីសំណាក់អាជ្ញាធរបាននាំឲ្យស្ត្រីយ៉ាងហោចណាស់បីនាក់សន្លប់។[30] ការបង្ក្រាបលើសកម្មជនសិទ្ធិដីធ្លី គឺត្រូវបានបង្ហាញផងដែរតាមរយៈករណីរបស់អ្នកស្រី យ៉ោម បុប្ផា ជាសកម្មជនបឹងកក់ លេចធ្លោមួយរូបដែលបានជាប់ពន្ធនាគាររយៈពេល៤៤៤ថ្ងៃពីបទល្មើសដែលអ្នកស្រីមិនបានប្រព្រឹត្ត។ កង្វះមូលដ្ឋានច្បាប់ដើម្បី ចោទប្រកាន់លើអ្នកស្រី បុប្ផា បាននាំឲ្យមានជំនឿជាទូទៅថា ករណីប្រឆាំងនឹងរូបអ្នកស្រី គឺត្រូវបានគេប្រឌិតឡើងក្នុងចេតនាដើម្បីបំបិទសំឡេងតវ៉ារបស់អ្នកស្រី។[31] ជាចុងក្រោយ អ្នកស្រី បុប្ផា ត្រូវបានដោះលែងឲ្យនៅក្រៅឃុំកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣។

<u>និទណ្ឌភាព និងកង្វះយន្តការដោះស្រាយជម្លោះ</u>

មានយន្តការដោះស្រាយជម្លោះដីធ្លីចំនួនប្រាំដែលកំពុងអនុវត្តនៅកម្ពុជា រួមមាន៖ តាមរយៈក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការរដ្ឋបាល គណៈកម្មការសុរិយោដី អាជ្ញាធរជាតិទទួលបន្ទុកដោះស្រាយជម្លោះដីធ្លី និង តុលាការ។ ប៉ុន្តែ តាមការកត់សម្គាល់របស់អ្នករាយការពិសេស គឺ លោក សូរិយា ស៊ូបេឌី ថា "*ការប្រើពេលវេលា បន្ទុកការងាររដ្ឋបាល និងនីតិវិធី តម្លៃប្រាក់ពាក់ព័ន្ធទៅនឹងការបញ្ជូនពាក្យបណ្តឹង... ព្រមទាំងកង្វះទំនុកចិត្តក្នុងប្រព័ន្ធនេះ នាំឲ្យយន្តការទាំងនេះកំពុងតែត្រូវបានគេប្រើប្រាស់ពុំសូវសង្វាក់គ្នា*"។[32]កង្វះយន្តការដោះស្រាយទំនាស់ប្រកបដោយប្រសិទ្ធភាព និងឯករាជ្យ កង្វះការទទួលបានដំណោះស្រាយ បានបង្កឲ្យស្ថានការណ៍កាន់តែយ៉ាប់យឺនតាមរយៈនិទណ្ឌភាព និងកង្វះឯករាជ្យភាពរបស់ស្ថាប័នតុលាការ។ ព្រឹត្តិការណ៍នៃអំពើហិង្សា ការជំរិត និងការរំលោភលើសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋពីសំណាក់អាជ្ញាធរ គឺកម្រនឹងត្រូវបានស៊ើបអង្កេត។

ប្រជាពលរដ្ឋនៅទីជនបទពិតជាងាយរងគ្រោះខ្លាំងណាស់ នៅពេលបានប្រឈមមុខនឹងបញ្ហា ដីធ្លីជាមួយនឹងអ្នកដែលអាចរួចទោសបានទាំងស្រុងនោះ។ ករណីរបស់អ្នកស្រី ហ៊ុយ ម៉ៃ នៅភូមិបុស្ស ខេត្តឧត្តរមានជ័យ គឺជាឧទាហរណ៍ស្រាប់។ នៅក្នុងខែតុលា ឆ្នាំ២០០៩ អ្នកស្រី ហ៊ុយ ម៉ៃ និងគ្រួសាររបស់អ្នកស្រីជាមួយនិងគ្រួសារចំនួន ១១៨ ដទៃទៀតនៅក្នុងភូមិ ត្រូវបានអាជ្ញាធរបណ្តេញចេញពីដីធ្លីដោយបង្ខំ ដែលជាផ្នែកនៃសម្បទានដីសេដ្ឋកិច្ច ត្រូវបានប្រគល់ទៅឲ្យក្រុមហ៊ុន *ស្អាអង្គរ។* លំនៅដ្ឋានរបស់អ្នកភូមិត្រូវបានដុតចោល ហើយភោគៈ និងដីកសិដ្ឋានត្រូវបានបំផ្លិចបំផ្លាញ។ បើទោះជាមានការសន្យាថា អ្នកស្រីនឹងទទួលបានប្លង់ដីដទៃនោះក្តី រហូតមកទល់ពេលនេះ

---

[29] លីកាដូ "សិទ្ធិមនុស្សនៅឆ្នាំ២០១២៖ ឆ្នាំត្រួតពិនិត្យ" (ខែកុម្ភៈ ឆ្នាំ២០១៣) អាចរកបានតាម៖ <http://bit.ly/1j3iWV6>។

[30]ឃុត សុភ័ក្រចរិយា "នគរបាលវាយដំលើសកម្មជនបុរីកីឡាដែលបិទផ្លូវ" កាសែត ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ អាចរកបានតាម៖ <http://bit.ly/1cnp38p>។

[31] ម.ស.ម.ក "ការវិភាគផ្លូវច្បាប់លើករណីចោទប្រកាន់ និងកាត់ទោសសកម្មជនការពារសិទ្ធិដីធ្លី អ្នកស្រី យ៉ោម បុប្ផា (សំណុំព្រហ្មទណ្ឌលេខ ១៥៦០) (ការវិភាគផ្លូវច្បាប់) (ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៣) អាចរកបានតាម៖ <http://bit.ly/OYKKma>។

[32] លោកប្រាសាទ សូរិយា ស៊ូបេឌី "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បន្ថែម៖ ការវិភាគផ្នែកសិទ្ធិមនុស្ស និងសម្បទានដីដទៃទៀតនៅក្នុងប្រទេសកម្ពុជា ក/គ.ស.ម/២១/៦៣/បន្ថែម.១/ដំណោះស្រាយ.១ (ថ្ងៃទី១០ ខែតុលា ឆ្នាំ ២០១២) អាចរកបានតាម៖ <http://bit.ly/17FL8bq>។

អ្នកស្រីមិនទទួលបានដីធ្លី ឬសំណងណាមួយនោះឡើយ ដែលធ្វើឲ្យអ្នកស្រី និងកូនៗគ្មានលំនៅដ្ឋាន ហើយបានធ្លាក់ខ្លួនក្រីក្រ។ នៅពេលដែល អ្នកស្រី ហ៊ុយ ម៉ៃ មានផ្ទៃពោះប្រាំខែ អ្នកស្រីបានព្យាយាមប្តឹងតវ៉ាទៅកាន់អាជ្ញាធរនានានៅក្នុងរាជធានីភ្នំពេញ ហើយអ្នកស្រី ត្រូវបានចោទប្រកាន់ពីបទរំលោភបំពានលើច្បាប់ព្រៃឈើ ហើយអ្នកស្រីបានជាប់ពន្ធនាគារ។ អ្នកស្រីបានសម្រាលកូនក្នុងពន្ធនាគារ។ ជំនួសពីការទទួលបានការជំនុំជម្រះដោយយុត្តិធម៌បន្ទាប់ពីស្ថិតនៅក្នុងការឃុំខ្លួនរយៈពេល៨ខែ តុលាការបានប្រាប់អ្នកស្រី ម៉ៃ ថា អ្នកស្រីនឹងត្រូវដោះលែងវិញបើសិនជាអ្នកស្រីបានចុះហត្ថលេខាព្រមព្រៀងដកពាក្យបណ្តឹងទាំងអស់ពាក់ព័ន្ធនឹងដីធ្លី នៅភូមិបុស្ស ហើយព្រមទទួលដីថ្មីជំនួស។[33]

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ស្ថានភាពរំលោភសិទ្ធិដីធ្លីធ្ងន់ធ្ងរនៅកម្ពុជា បានកើតឡើងដោយសារកត្តាផ្សេងៗ ជាច្រើន រួមទាំង ប្រវត្តិដ៏ស្មុគស្មាញរបស់កម្ពុជានោះផង។ តែយ៉ាងណាក្តី នៅទីបំផុតការទទួលខុសត្រូវនៃការកើនឡើងនូវទំនាស់ដីធ្លីនៅទូទាំងប្រទេសនេះ គឺជាបន្ទុករបស់ រដ្ឋាភិបាល។ រដ្ឋាភិបាលអនុវត្តក្នុងលក្ខណៈមួយខ្វះតម្លាភាព ដោយរំលោភច្បាប់ និងប្រើអំពើហិង្សាលើប្រជាពលរដ្ឋខ្លួនឯងជាមួយនឹងនិទណ្ឌភាពទាំងស្រុង ដែលប្រការនេះ បានធ្វើឲ្យប៉ះពាល់ខ្លាំងបំផុតទៅលើប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលងាយទទួលរងគ្រោះនៅកម្ពុជា។

រដ្ឋាភិបាលត្រូវធានាថា ច្បាប់ដែលមានជាធរមានត្រូវតែ អនុវត្តយ៉ាងត្រឹមត្រូវ ពីសំណាក់អាជ្ញាធររដ្ឋ និងវិស័យឯកជនផង។ ការអនុវត្តនេះ ពិតជាត្រូវធ្វើឡើងតាមរយៈសកម្មភាពបន្ទាន់ និងទូលំទូលាយរបស់រាជរដ្ឋាភិបាលដែលចាំបាច់បំផុតក្នុងការធ្វើកំណែទម្រង់ដីធ្លី ដើម្បីឲ្យរដ្ឋាភិបាលអាចបំពេញកាតព្វកិច្ចសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋរបស់ខ្លួន ក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ម.ស.ម.ក សូមផ្តល់អនុសាសន៍ជូនទៅរដ្ឋាភិបាលដូចខាងក្រោមនេះ៖

តម្លាភាព ៖ រដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ គួរតែ៖

- ដាក់បង្ហាញជាសាធារណៈ និងអាចចូលទៅរកបាននូវព័ត៌មានទាំងឡាយពាក់ព័ន្ធនឹងសម្បទានដីដែលមានស្រាប់និងសម្បទានដីដែលត្រូវបានលុបចោល។
- ដាក់បង្ហាញជាសាធារណៈនូវព័ត៌មានស្តីពីការរៀបចំប្លង់ ការធ្វើចំណាត់ថ្នាក់ និងការចុះបញ្ជីដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ក៏ដូចជាព័ត៌មានទាំងឡាយពាក់ព័ន្ធនឹងការធ្វើអនុប្បយោគ។
- ដាក់បង្ហាញជាសាធារណៈនូវបញ្ជីថ្មីនៃតំបន់នានាដែលត្រូវការពារ។
- ធានាថាការធ្វើអនុប្បយោគដីសាធារណៈរបស់រដ្ឋ និងតំបន់ប្រើប្រាស់ចីរកាល ប្រកបដោយតម្លាភាព និងមានលក្ខណៈបើកចំហ។
- ធានាថាដីសម្បទានត្រូវធ្វើឡើងឲ្យស្របតាមនីតិវិធី មានលក្ខណៈប្រកួតប្រជែង និងតម្លាភាព។

[33] អង្គការលើកលែងទោសអន្តរជាតិ "ការបណ្តេញ និងការប្រឆាំងនៅកម្ពុជា៖ ស្ត្រីប្រាំរូបប្រាប់រឿងរ៉ាវរបស់ពួកគេ" (ខែវិច្ឆិកា ឆ្នាំ២០១១) អាចរកបានតាម៖<http://bit.ly/1foO8xF>។

- បន្តការផ្អាកផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងដាក់បង្ហាញជាសាធារណៈនូវចំនួនសម្បទានដីសេដ្ឋកិច្ចដែលបានអនុវត្តចាប់តាំងពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ និងធ្វើការសើរើប្រព័ន្ធសម្បទាន ជាសាធារណៈ និង
- អនុម័តច្បាប់ស្តីពីការទទួលបានព័ត៌មានដើម្បីធ្វើឲ្យមានតម្លាភាព និងមានការចូលរួមជាសាធារណៈ។

សន្តិសុខនៃកម្មសិទ្ធិ - រដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ គួរតែ៖

- ដោះស្រាយនូវរាល់ទំនាស់ដីធ្លីជាចម្បងហើយជៀសវៀងការបដិសេធឲ្យពលរដ្ឋទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីតាមរយៈកម្មវិធីរបស់រាជរដ្ឋាភិបាល។
- បញ្ឈប់ប្រើនិស្សិតស្ម័គ្រចិត្ត និងដាក់ជំនួសមកវិញនូវអ្នកដែលមានបទពិសោធន៍ និងមានការបណ្តុះបណ្តាលត្រឹមត្រូវ។
- គោរពកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ និងសិទ្ធិភោគៈអនុលោមតាមច្បាប់ភូមិបាល។
- ពន្លឿនដំណើរការចុះបញ្ជីដីធ្លីដល់សហគមន៍ជនជាតិដើមភាគតិច ជាលក្ខណៈនីតិបុគ្គល ព្រមទាំងចុះបញ្ជីប័ណ្ណដីធ្លីសមូហភាព ហើយបញ្ឈប់ការផ្តល់សម្បទានដីរបស់ជនជាតិដើមភាគតិច មុនពេលដំណើរការនៃការចុះបញ្ជីដីសមូហភាពចប់សព្វគ្រប់។
- ធានាឲ្យមានការអនុវត្តតាមបទបញ្ជាលេខ០១ មិនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាព។
- ធានានូវសម្បទានដោយធ្វើឡើងគ្រប់វិធានការដើម្បីបញ្ចៀសពីផលប៉ះពាល់បរិស្ថាន និង
- រារាំងសកម្មភាពនានានៅលើតំបន់វប្បធម៌ និងទំនៀមទម្លាប់សាសនា។

ការពិគ្រោះយោបល់ -រាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ គួរតែ៖

- រៀបចំឲ្យមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ច្បាស់លាស់ និងជាសាធារណៈជាមួយភាគីពាក់ព័ន្ធ ព្រមទាំងជាមួយសហគមន៍ដែលបានរងផលប៉ះពាល់ និងនៅពេលដែលសម្បទានដី និងគម្រោងអភិវឌ្ឍបានចាប់ផ្តើមឡើង។ ការពិគ្រោះយោបល់ត្រូវតែធ្វើឡើងក្នុងដំណាក់កាលមុនដំបូងបំផុត និង ធ្វើសេចក្តីសម្រេចចិត្តឲ្យបានល្អិតល្អន់ ហើយនិង,
- វាយតម្លៃពីផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាននៃគម្រោងអភិវឌ្ឍមានទ្រង់ទ្រាយធំ អនុលោមតាមបទដ្ឋានអន្តរជាតិ មុនពេលផ្តល់សម្បទានដី និងក្នុងដំណាក់កាលពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់។

ការបណ្តេញចេញដោយបង្ខំ -រាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ គួរតែ៖

- ធានាថាការបណ្តេញចេញធ្វើឡើងតែក្នុងមធ្យោបាយចុងក្រោយប៉ុណ្ណោះ។
- អនុវត្តបន្តការផ្អាកជាបណ្តោះអាសន្នលើការបណ្តេញចេញ រហូតដំណើរការនៃការផ្តល់ប័ណ្ណកម្មសិទ្ធិបានចប់សព្វគ្រប់។

- ធានាថាទីកន្លែងប្តូរទៅតាំងលំនៅដ្ឋានថ្មីទាំងអស់នោះ មានសេវាមូលដ្ឋាន រួមទាំង ការទទួលបានភ្លើង ទឹក អនាម័យ សេវាអប់រំសាធារណៈ សុខភាព និងសេវាសន្តិសុខ។
- ធានាឲ្យមានជំនួយផ្នែកថវិកា លំនៅដ្ឋានសមរម្យ និងសំណងត្រឹមត្រូវជូនដល់សហគមន៍ដែលបានទទួលរងផលប៉ះពាល់។
- ធានាថាប្រជាពលរដ្ឋបណ្តេញចេញដែលតាំងទីលំនៅថ្មីនោះត្រូវបានគេផ្តល់បណ្ណដីធ្លីដើម្បីធានាថាពួកគាត់នឹងមិនត្រូវបានទទួលការគំរាមបណ្តេញចេញជាថ្មីទៀត និង
- ធានាថាក្រុមហ៊ុនសម្បទានមិនប្រើកម្លាំងប្រដាប់អាវុធរបស់រដ្ឋដើម្បីការពារក្រុមហ៊ុន។

ការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព- រាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ គួរតែ៖

- ពង្រឹងយន្តការដោះស្រាយទំនាស់ដែលមានស្រាប់។
- ស៊ើបអង្កេត ហើយប្រសិនបើចាំបាច់ គួរតែផ្តន្ទាទោសតួអង្គឯកជនដែលទទួលខុសត្រូវចំពោះការចាប់យកដីធ្លី ការបណ្តេញចេញដោយខុសច្បាប់ និងការមិនអនុវត្តតាមច្បាប់។
- កងកម្លាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលត្រូវតែប្រកាន់ខ្ជាប់ទទួលខុសត្រូវចំពោះការប្រើកម្លាំងហួសហេតុប្រឆាំងនឹងប្រជាពលរដ្ឋ និង,
- ធ្វើការងារដើម្បីធានានូវឯករាជ្យភាពរបស់តុលាការដើម្បីកម្រិតឥទ្ធិពលផ្នែកនយោបាយ។

សិទ្ធិសេរីភាពខាងការបញ្ចេញមតិ ជួបប្រជុំ និងបង្កើតសមាគម - រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ គួរតែ៖

- ជួយសម្រួលការងាររបស់អង្គការសង្គមស៊ីវិលក្នុងការស៊ើបអង្កេតករណីរំលោភបំពានដីធ្លី និងករណីបណ្តេញប្រជាពលរដ្ឋចេញពីដីធ្លី។
- បញ្ឈប់នូវរាល់ការយាយីផ្នែកនយោបាយ និងតាមផ្លូវតុលាការ ព្រមទាំងអំពើហិង្សាប្រឆាំងទៅលើអ្នកតវ៉ាដោយសន្តិវិធី និង,
- ដោះលែងតំណាងសហគមន៍ និងអ្នកគាំទ្រសិទ្ធិដីធ្លី ដែលត្រូវបានអាជ្ញាធរឃុំខ្លួន ឬដាក់ពន្ធនាគារបច្ចុប្បន្ននេះទាំងអស់ជាបន្ទាន់ ដើម្បីឲ្យអ្នកទាំងនោះអាចអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំរបស់ខ្លួនបាន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក វណ្ណ សុផាត មន្ត្រីសម្របសម្រួលគម្រោងកំណែទម្រង់ដីធ្លីរបស់ ម.ស.ម.ក តាមរយៈទូរសព្ទ៖ +៨៥៥ (០) ១២ ៩៤១ ២០៦ ឬអ៊ីម៉ែល៖ vann.sophath@cchrcambodia.org ឬលោកស្រី អ៊ីលីស ជីលាត តាមរយៈទូរសព្ទ៖ +៨៥៥(០) ៧៧៧០ ៩៧២៣ ឬអ៊ីម៉ែល៖ elise.tillet@cchrcambodia.org។